អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ២០១៨

# សេចក្តីថ្លែងការណ៍ដោយសហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីសំណុំរឿង ០០៤

នៅថ្ងៃទី៣១ ខែឧសភា និងថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពរក្នុងសំណុំរឿង០០៤ រៀងៗខ្លួន ទាក់ទងនឹងកិច្ចស៊ើបសួរលើ យឹម ទិត្យ។ វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ចែងថា ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាត្រូវដាក់ជាការសម្ងាត់ ប៉ុន្តែសហព្រះរាជអាជ្ញាអាចបង្ហាញដល់សាធារណជនបាននូវសេចក្តីសង្ខេបពីគោលបំណងនៃដីកាសន្និដ្ឋានរបស់ខ្លួន។ ជាផលប្រយោជន៍ដល់តម្លាភាពចំពោះចំណាប់អារម្មណ៍ជាសាធារណៈ សហព្រះរាជអាជ្ញាអន្តរជាតិ (“ស.ព.អ”) សូមផ្តល់ជូននូវសេចក្តីសង្ខេបអំពីដីកាសន្និដ្ឋានស្ថាពររបស់គាត់ដូចខាងក្រោម។ សេចក្តីសង្ខេបនេះ មិនរាប់បញ្ចូលទស្សនៈយល់ឃើញរបស់សហព្រះរាជអាជ្ញាជាតិទេ (ដែលបានធ្វើសេចក្តីសង្ខេបក្នុងសេចក្តីសង្ខេបដោយឡែក) ឬរបស់មេធាវីការពារក្តីនោះដែរ និងទោះបីជានៅក្នុងករណីណាក៏ដោយ ក៏មិនមានចេតនាដើម្បីឆ្លុះបញ្ចាំងពីមតិយោបល់របស់សហចៅក្រមស៊ើបអង្កេតដែរដែលពួកគាត់នឹងធ្វើការកំណត់លើបញ្ហាទាំងនេះដោយផ្ទាល់ខ្លួនរបស់ពួកគាត់។

## <u>សេចក្តីសន្និដ្ឋានរបស់ ស.ព.អ ស្តីពីយុត្តាធិការរបស់ អ.វ.ត.ក លើ យឹម ទិត្យ</u>

ច្បាប់គ្រប់គ្រង អ.វ.ត.ក ចែងថា តុលាការមានយុត្តាធិការលើបុគ្គលណាម្នាក់បានឲ្យតែបុគ្គលនោះជា “មេដឹកនាំជាន់ខ្ពស់” ឬ ជនទាំងឡាយដែល “ទទួលខុសត្រូវខ្ពស់បំផុត” ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយខ្មែរក្រហម។ ស.ព.អ សន្និដ្ឋានថា តាមទស្សនៈយល់ឃើញរបស់គាត់ដោយផ្អែកលើភស្តុតាង យឹម ទិត្យ គឺជា “មេដឹកនាំជាន់ខ្ពស់” កម្ពុជាប្រជាធិបតេយ្យផង និងជាជនម្នាក់នៃជនទាំងឡាយដែល “ទទួលខុសត្រូវខ្ពស់បំផុត”ផង ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរបបនេះ សម្រាប់មូលហេតុដូចបានសង្ខេបខាងក្រោម។

យឹម ទិត្យ គឺជាកម្មាភិបាលដ៏មានអំណាចបំផុតម្នាក់នៅក្នុងបក្សកុម្មុយនីសកម្ពុជា ("ប.ក.ក") ដោយកាន់មុខតំណែងជាន់ខ្ពស់ជាច្រើននៅទូទាំងភូមិភាគចំនួនពីរ ដូច្នេះគាត់ត្រួតត្រាលើចំណែកដ៏ធំនៃប្រជាជនសរុបរបស់កម្ពុជាប្រជាធិបតេយ្យ។

នៅក្នុងអំឡុងពេលដំបូងនៃរបបនេះ យឹម ទិត្យ គឺជាបុគ្គលមានអំណាចម្នាក់នៅភូមិភាគនិរតី ដោយបានឡើងពីអនុលេខាស្រុកគិរីវង់ ដល់លេខាស្រុក និងបន្ទាប់មកទៀតបានឡើងជាអនុលេខា និងលេខាតំបន់១៣។ គាត់បានត្រួតត្រាបណ្តាស្រុកនានាដែលមានមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សជាច្រើនស្ថិតនៅក្នុងនោះ។ ប្រហែលជាក្នុងឆ្នាំ១៩៧៧ នៅពេលដែលថ្នាក់ដឹកនាំមជ្ឈិម ប.ក.ក បានចាប់ផ្តើមធ្វើការបោសសម្អាតកម្មាភិបាលរបស់ខ្លួនផ្ទាល់នៅភូមិពាយ័ព្យនោះ យឹម ទិត្យ ក៏បានឡើងគ្រប់គ្រងអំណាចនៅលើផ្នែកដ៏ធំនៃភូមិភាគពាយ័ព្យ រួមមាន តំបន់១, ២, ៣, ៤ និងតំបន់៧ ហើយគាត់ជាចុងក្រោយក៏ត្រូវបានតែងតាំងជាអនុលេខាភូមិភាគ។ ជាការបន្ថែម គាត់បានធ្វើជាលេខាភូមិភាគស្តីទី នៅពេលអវត្តមាន តាម៉ុក ដែលជាមនុស្សចូលចិត្តធ្វើដំណើរទៅខាងក្រៅតំបន់ជាញឹកញាប់។ តាមរយៈមុខតំណែងទាំងនេះ យឹម ទិត្យ បានបញ្ជា និងជួយសម្រួលដល់ឧក្រិដ្ឋកម្មនានា ដែលជាលទ្ធផល បណ្តាលឲ្យមានការប្រព្រឹត្តអំពើយុងឃ្នងក្នុងទ្រង់ទ្រាយធំនៅភូមិភាគពាយ័ព្យ។ ជាមួយគ្នានេះដែរ យឹម ទិត្យ នៅរក្សាអំណាចរបស់គាត់ និងមានឥទ្ធិពលជាប់រហូតមកក្នុងតំបន់១៣នៃភូមិភាគនិរតី ជាទីកន្លែងដែលផែនការឧក្រិដ្ឋកម្មដូចគ្នា ត្រូវបានអនុវត្តដោយសមាជិកនៃសហឧក្រិដ្ឋកម្មរួមដូចគ្នា។

យឹម ទិត្យ ក៏ជាជនម្នាក់ក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងកម្ពុជាប្រជាធិបតេយ្យផងដែរ រួមទាំងអំពើប្រល័យពូជសាសន៍ផង ហើយគាត់បានដើរតួនាទីសំខាន់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។ យឹម ទិត្យ បានជួយបង្កើតឲ្យចេញជារូបរាង និងធ្វើឲ្យកាន់តែដុះដាលនូវគោលនយោបាយឧក្រិដ្ឋនានា ព្រមទាំងបានធានាថា គោលនយោបាយទាំងនោះត្រូវបានអនុវត្តដោយអ្នកនៅក្រោមបង្គាប់របស់គាត់។ តាមទស្សនៈរបស់ ស.ព.អ មានភស្តុតាងបង្ហាញអំពីការពាក់ព័ន្ធដោយផ្ទាល់របស់ យឹម ទិត្យ ជាមួយនឹងឧក្រិដ្ឋកម្មទាំងនោះ និងរួមមានទាំងភស្តុតាងដែលបង្ហាញថា ខ្លួនគាត់ផ្ទាល់ធ្លាប់ចេញបញ្ជាឲ្យសម្លាប់។

## <u>សេចក្តីសន្និដ្ឋានរបស់ ស.ព.អ ចំពោះឧក្រិដ្ឋកម្ម និងការទទួលខុសត្រូវរបស់ យឹម ទិត្យ</u>

ស.ព.អ ទាញអំណះអំណាងថា យឹម ទិត្យ គួរតែត្រូវបានចោទប្រកាន់នាំខ្លួនទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម និងក្រុមខ្មែរក្រោមនៅកម្ពុជា និងចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរ

ឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ជាពិសេស ការធ្វើបាបដោយអមនុស្សធម៌ ការបញ្ជូនដោយបង្ខំ អាពាហ៍ពិពាហ៍ដោយបង្ខំ អំពើរំលោភសេពសន្ថវៈក្នុងបរិបទនៃអាពាហ៍ពិពាហ៍ ការរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ)។

ភ័ស្តុតាងដែលប្រមូលបានក្នុងពេលស៊ើបអង្កេតបានកំណត់អំពីការរួមចំណែករបស់ យឹម ទិត្យ នៅក្នុងសហឧក្រិដ្ឋកម្មនៅភូមិភាគនិរតី និងពាយ័ព្យ ទាក់ទងនឹងមន្ទីរសន្តិសុខចំនួន១៧កន្លែង ទីតាំងសម្លាប់មនុស្ស៨កន្លែង ការដ្ឋានការងារដោយបង្ខំ៤កន្លែង និងទីតាំងបន្ថែម៣ទៀត (រោងចក្រស្តុកសកំពង់គល់ ឃុំវាំងកេសី និងអំពើហិង្សាផ្លូវភេទក្នុងស្រុកបាណន់។ ភ័ស្តុតាងក្នុងសំណុំរឿងបញ្ជាក់ថា ឧក្រិដ្ឋកម្មនានាត្រូវបានប្រព្រឹត្តឡើងក្នុងរបៀបស្រដៀងគ្នាបេះបិទនៅទូទាំងភូមិភាគដែល យឹម ទិត្យ បានធ្វើប្រតិបត្តិការ។ នៅតាមមន្ទីរសន្តិសុខ អ្នកជាប់ឃុំត្រូវបានគេដាក់ក្នុងមន្ទីរឃុំឃាំងដោយគ្មានដំណើរការច្បាប់ត្រឹមត្រូវ និងជាញឹកញាប់ត្រូវបានគេដាក់ឱ្យស្ថិតក្រោមការធ្វើបាបដោយអមនុស្សធម៌ដែលរួមមាន លក្ខខណ្ឌរស់នៅគ្មានអនាម័យគ្មានអាហារគ្រប់គ្រាន់ អំពើហិង្សាផ្លូវកាយ និងគ្មានការថែទាំវេជ្ជសាស្ត្រគ្រប់គ្រាន់។ នៅឯការដ្ឋានការងារដោយបង្ខំ កម្មកររស់នៅក្រោមលក្ខខណ្ឌនៃភាពជាទាសករ។ ពួកគេគ្មានសិទ្ធិសេរីភាពអ្វីទាំងអស់ ពួកគេត្រូវបានផ្តល់ការងារដ៏លំបាក ដោយគេបានរំពឹងទុកថា នឹងបំពេញបានតាមចំនួនដែលគេបានកំណត់ដែលគេមិនប្រាកដថាអាចធ្វើបាន ធ្វើការបែបអមនុស្សធម៌ជាច្រើនម៉ោងជាមួយអាហារ ការសម្រាក ឬការថែទាំផ្នែកវេជ្ជសាស្ត្រមិនគ្រប់គ្រាន់។ ទាំងនៅមន្ទីរសន្តិសុខ និងទាំងនៅការដ្ឋានការងារដោយបង្ខំ មនុស្សជាច្រើនបានស្លាប់ដោយសារលក្ខខណ្ឌរស់នៅ និងការងារយ៉ាងអាក្រក់។ មនុស្សច្រើនពាន់នាក់ ត្រូវបានសម្លាប់ដោយគ្មានដំណើរការតាមផ្លូវតុលាការ។

*ឧក្រិដ្ឋកម្មនៅភូមិភាគនិរតី ដែល យឹម ទិត្យ ត្រូវទទួលខុសត្រូវ*

**តំបន់ ១៣**

1. <u>មន្ទីរសន្តិសុខវត្តព្រះធាតុ</u> គឺជាគុកមួយស្ថិតក្រោមការត្រួតត្រារបស់គណៈស្រុកគិរីវង់ ជាទីកន្លែងដែលបានឃុំឃាំងខ្មែរក្រោម និង "ប្រជាជន ១៧ មេសា" ជាច្រើននាក់។ យឹម ទិត្យ ធ្លាប់បានសួរចម្លើយ អ្នកជាប់ឃុំដោយផ្ទាល់នៅលើទីតាំងនេះ។ យ៉ាងហោចណាស់ ក៏ចាប់តាំងពីឆ្នាំ១៩៧៦មកដែរ ដែលខ្មែរក្រហម បានអនុវត្តការកាប់សម្លាប់នៅវត្តព្រះធាតុដោយធ្វើឡើងជារៀងរាល់សប្តាហ៍។ មានជនរងគ្រោះប្រហែល ៩០០នាក់ ត្រូវបានប៉ាន់ប្រមាណថាត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខនេះតែមួយគត់។

2. នៅឯ<u>ទីតាំងសម្លាប់មនុស្សវត្តអង្គុញ</u> ក្នុងស្រុកគិរីវង់ ជនរងគ្រោះដែលគេបានសម្លាប់ រួមមានទាំងកុមារពីអង្គភាពនានាដែលរស់នៅចំណុះឲ្យជើងវត្តនេះ ខ្មែរក្រោមដែលគេបញ្ជូនមកពីភ្នំពេញ ខ្មែរក្រោមដែលគេជម្លៀសមកពីវៀតណាម និងអតីតទាហាន លន់ នល់។

3. <u>វត្តស្លែង និងភូមិព្រាល</u> គឺជាទីតាំងសម្លាប់មនុស្សស្ថិតក្នុងស្រុកគិរីវង់។ ឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ខ្មែរក្រោមមួយចំនួនធំដែលត្រូវបានគេនិរទេសពីវៀតណាម ត្រូវបានបញ្ជូនដោយបង្ខំទៅកាន់ភូមិទាំងនេះ ហើយក៏បានសម្លាប់ចោល។

4. <u>នៅមន្ទីរសន្តិសុខក្រាំងតាចាន់</u>ក្នុងស្រុកត្រាំកក់ អ្នកជាប់ឃុំ រួមមាន "ពួក១៧មេសា" អតីតមន្ត្រីរដ្ឋការ លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ កម្មាភិបាល ប.ក.ក និង "ប្រជាជនមូលដ្ឋាន"។ នៅឆ្នាំ១៩៧៦ មានខ្មែរក្រោម និង "ប្រជាជន១៧មេសា" ត្រូវបានជម្លៀសមកពីស្រុកគីរីវង្សទៅក្រាំងតាចាន់។ មន្ទីរសន្តិសុខត្រូវបានរំខានរុករានដោយសត្វល្អិតស្មោកគ្រោកចង្រៃ ហើយអ្នកទោសត្រូវបានដាក់ឲ្យស្ថិតនៅក្រោមអំពើហិង្សាខាងរាងកាយជាប់ជាប្រចាំ។ អ្នកទោសជាច្រើនត្រូវបានទទួលរងនូវអំពើទារុណកម្ម ហើយអ្នកជាប់ឃុំជាស្ត្រីមួយចំនួនត្រូវបានគេរំលោភសេពសន្ថវៈ។ អ្នកទោសជាច្រើនពាន់នាក់ត្រូវបានសម្លាប់នៅក្រាំងតាចាន់ ហើយមានអ្នកទោសមួយចំនួនតូចប៉ុណ្ណោះដែលនៅរស់រានមានជីវិត។

5. <u>មន្ទីរសន្តិសុខវត្តអង្គស្រីមុន្នី និងទីកន្លែងសម្លាប់មនុស្សព្រៃសុខុន</u> ស្ថិតនៅក្នុងស្រុកកោះអណ្តែត។ ជនរងគ្រោះដែលបានជាប់ឃុំនៅវត្តនោះ រួមមាន "ប្រជាជន១៧មេសា" អតីតមន្ត្រីរដ្ឋការ លន់ នល់ និងក្រុមគ្រួសាររបស់ពួកខ្មែរក្រោម ដែលត្រូវបានគេជម្លៀសដោយបង្ខំពីទីក្រុងភ្នំពេញ និងពីក្រុងតាកែវ។ ពួកអ្នកជាប់ឃុំត្រូវបានសម្លាប់ជារៀងរាល់ថ្ងៃនៅព្រៃសុខុន ហើយសាក្សីបានប៉ាន់ប្រមាណថាមានមនុស្សរាប់ពាន់នាក់ត្រូវបានសម្លាប់នៅទីកន្លែងនោះ។

*ឧក្រិដ្ឋកម្មនៅភូមិភាគពាយ័ព្យ ដែល យឹមទិត្យ ត្រូវទទួលខុសត្រូវ*

**តំបន់១**

6. <u>មន្ទីរសន្តិសុខគាស់ក្រឡ</u> ត្រូវបានបង្កើតឡើងនៅដើមឆ្នាំ១៩៧៨។ គេអាចដាក់អ្នកទោសបានរហូតដល់ទៅ៣០០នាក់ រួមមាន សមាជិកអតីតរបប លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ, កម្មាភិបាលភូមិភាគពាយ័ព្យនិងក្រុមគ្រួសាររបស់ពួកគេ និង "ប្រជាជន១៧មេសា"។ ការសម្លាប់ជាច្រើនបានកើតឡើងនៅទីកន្លែងនោះ រួមមានយ៉ាងហោចណាស់ ការសម្លាប់រង្គាលចំនួនបីដង ដែលក្នុងម្តងៗមានអ្នកទោស ៧៥

នាក់ ឬច្រើនជាងនេះ។ នៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ មានសាកសពមនុស្សរាប់រយនាក់ត្រូវបានគេឃើញកប់ក្នុងរណ្ដៅនៅទីកន្លែងនោះ។

7. <u>សហករណ៍ធិបតី</u>ក្នុងស្រុកគាស់ក្រឡ ដែលត្រូវបានគ្រប់គ្រងដោយ យឹម ទិត្យ មានទីកន្លែងពលកម្មដោយបង្ខំមួយចំនួន មានមន្ទីរឃុំឃាំងចំនួនបួនយ៉ាងតិច និងទីកន្លែងសម្លាប់មនុស្សមួយចំនួន។ ពលកររាប់ពាន់នាក់ពីតំបន់១ និងតំបន់៤ រួមមាន អតីតកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ ពួកខ្មែរក្រោម និង "ប្រជាជន១៧មេសា" បានធ្វើការលើសជាច្រើនម៉ោងនៅតាមសហករណ៍ដោយមានការសម្រាកតិចតួច។ ពួកអ្នកដែលមិនអាចធ្វើបានតាមលក្ខខណ្ឌតម្រូវការងាររបស់ ប.ក.ក ត្រូវបានគេចាត់ទុកថាជា "ខ្មាំង" និងត្រូវបានបោសម្អាត "ត្រូវបានរៀនសូត្រ" ឬ ត្រូវបានសម្លាប់ចោល។ ពួកកម្មាភិបាលភូមិភាគពាយ័ព្យដែលត្រូវបានបញ្ចុះសក្តិនៅទូទាំងតំបន់១ ត្រូវបានធ្វើឱ្យទៅជាទាសករ ឬត្រូវបានដាក់នៅក្នុងមន្ទីរឃុំឃាំងនៅភូមិទួលម្ទេស និងជាច្រើននាក់ត្រូវបានសម្លាប់ចោល។ នៅមន្ទីរសន្តិសុខធិបតី ពួកអ្នកទោសត្រូវបានគេធ្វើទារុណកម្ម ហើយនៅជិតចប់របប ពួកអ្នកទោសដែលនៅសេសសល់ទាំងអស់ត្រូវបានគេសម្លាប់ចោល។ នៅភូមិរ៉ា យ៉ាងហោចណាស់ មានសាកសពមនុស្ស២០០នាក់ត្រូវបានគេឃើញនៅជិតកន្លែងមន្ទីរឃុំឃាំង និងនៅក្បែរមន្ទីរសន្តិសុខមួយនៅភ្នំតាចុក ពួកអ្នកទោសត្រូវបានបាត់ខ្លួន និងមិនត្រូវបានគេឃើញម្តងទៀតឡើយ។

8. <u>ទំនប់កង្ហត</u>ក្នុងស្រុកសង្កែ គឺជាទីកន្លែងពលកម្មមួយដែលគណៈតំបន់ រួមមាន យឹម ទិត្យ ផងនោះ បានត្រួតពិនិត្យជាប់ជាប្រចាំ។ យឹម ទិត្យ បានត្រួតពិនិត្យទីកន្លែងនោះនៅពាក់កណ្តាលខែកក្កដា ឆ្នាំ១៩៧៧ និងសូម្បីតែតាំងពីមុនពេលដែលគាត់បានទៅធ្វើទស្សនកិច្ចទំនប់ និងបើកកិច្ចប្រជុំនៅទីនោះទៅទៀត។ ពលកររាប់រយនាក់ និងអាចមានរហូតដល់ទៅរាប់ពាន់នាក់ រួមមាន ពួកកម្មាភិបាលភូមិភាគពាយ័ព្យដែលត្រូវបានបញ្ចុះសក្តិ បានលើកទំនប់នោះ។ អ្នកដែលត្អូញត្អែរ អ្នកដែលធ្វើមិនបានតាមកូតា ឬអ្នកដែលយកម្ហូបអាហារដោយមិនមានការអនុញ្ញាត ត្រូវបានចាប់ខ្លួន ឬក៏សម្លាប់ចោល។ ការស្លាប់បានកើតឡើងជាប់ជាប្រចាំ។ បន្ថែមលើនេះ ពួកកម្មាភិបាលភូមិភាគពាយ័ព្យនៅគណៈតំបន់១ និងក្រុមគ្រួសារ និងអ្នកក្រោមបង្គាប់របស់ពួកគេ ត្រូវបានចាប់ខ្លួននៅទីកន្លែងនោះ និងយកទៅកាន់មន្ទីរឃុំឃាំង រួមទាំង ស-២១ នៅភ្នំពេញទៀតផង។

9. <u>នៅរោងចក្រស្តុកទឹកកំពង់គល់</u>ក្នុងស្រុកសង្កែ យឹម ទិត្យ បានដាក់ជំនួសប្រធានរោងចក្រដោយកម្មាភិ បាលភូមិភាគនិរតី។ នៅដើមខែវិច្ឆិកា ឆ្នាំ១៩៧៧ កម្មាភិបាលពាយ័ព្យដែលធ្លាប់បានបំរើនៅក្នុងគណៈរោង

ចក្រទាំងអស់ត្រូវបានបោសសម្អាត។ ខ្មែរក្រោម និងពួកកម្មករវៀតណាម ត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំង ហើយបន្ទាប់មក ត្រូវបានបញ្ជូនទៅសម្លាប់ចោល។

10. នៅមន្ទីរសន្តិសុខបាណន់ និងខ្នងគូ ក្នុងស្រុកសង្កែ បុគ្គលដែលត្រូវបានជាប់ឃុំឃាំងដោយមិនមាននីតិវិធីត្រឹមត្រូវតាមច្បាប់ និងត្រូវបានគេធ្វើទារុណកម្ម។ កម្មាភិបាលនិរតីបានជំនួសកម្មាភិបាលពាយ័ព្យនៅមន្ទីរសន្តិសុខបាណន់ ក្នុងឆ្នាំ១៩៧៧។ ពួកអ្នកជាប់ឃុំឃាំង រួមមាន អតីតមន្ត្រីរដ្ឋការ លន់ នល់ ពួកកម្មាភិបាលភូមិភាគពាយ័ព្យ ពួកវៀតណាម "ប្រជាជន១៧មេសា" និង ពួកកម្មករមកពីទីកន្លែងពលកម្មដោយបង្ខំនៅទំនប់កង្ហត។ នៅបាណន់ មានមនុស្សជាច្រើនរហូតដល់ទៅ ៥០០នាក់ ត្រូវបានជាប់នៅក្នុងឃុំ ហើយការសម្លាប់ចោលមានកើតឡើងជារៀងរាល់ថ្ងៃ។ នៅឆ្នាំ១៩៧៨ ពួកកម្មាភិបាលនិរតីបានផ្លាស់ប្តូរអ្នកទោសដែលនៅរស់រានមានជីវិតទាំងអស់ទៅកាន់មន្ទីរសន្តិសុខខ្នងគូ ជាកន្លែងដែលការសម្លាប់រង្គាលលើពួកអ្នកទោសបានកើតមានឡើង។

**តំបន់២**

11. មន្ទីរសន្តិសុខភូមិវាល ត្រូវបានត្រួតពិនិត្យដោយគណៈស្រុកបាកាន និងត្រូវបានប្រើប្រាស់ដើម្បីឃុំឃាំងពួក"ខ្មាំង"នៃកម្ពុជាប្រជាធិបតេយ្យ ដូចជា ខ្មែរក្រោម និងពួកជម្លៀសភូមិភាគបូព៌ា។ ពួកអ្នកទោសត្រូវបានគេធ្វើទារុណកម្ម និងអ្នកទោសស្រីមួយចំនួនត្រូវបានរំលោភសេពសន្ថវៈមុននឹងសម្លាប់ចោល។ ការសម្លាប់មនុស្សបានកើតឡើងជារៀងរាល់យប់ និងក្រុមមនុស្សដែលមានចំនួន ៤០០នាក់ និង ១៧០០នាក់ដែលបានបញ្ជូនមកពីភូមិភាគបូព៌ា ត្រូវបានសម្លាប់ចោលនៅភូមិវាល នៅជិតចុងបញ្ចប់នៃរបបនេះ។ ជាសរុប មានមនុស្សរាប់ពាន់នាក់ត្រូវបានសម្លាប់ចោលនៅទីកន្លែងនេះ។

12. នៅមន្ទីរសន្តិសុខស្វាយជ្រុំក្នុងស្រុកបាកាន អ្នកទោសជាច្រើនពាន់នាក់ត្រូវបានចាប់ឃុំឃាំង រួមមានអតីតកម្មាភិបាលភូមិភាគពាយ័ព្យ អតីតទាហាន លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ ខ្មែរក្រោម អ្នកជម្លៀសភូមិភាគបូព៌ា និង "ប្រជាជន១៧មេសា"។ ពួកអ្នកជាប់ឃុំត្រូវបានគេធ្វើទារុណកម្ម និងអ្នកទោស"ធ្ងន់" ត្រូវបានគេចាក់សោនៅក្នុង"គុកងងឹត"គ្មានបង្អួច ដោយអស់រយៈពេលយូរ។ គេប៉ាន់ប្រមាណថាមានអ្នកទោសរាប់ពាន់នាក់ត្រូវបានសម្លាប់នៅក្បែរៗទីកន្លែងសម្លាប់ព្រៃភាគ។

13. នៅទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ និងព្រៃក្របៅ ក្នុងស្រុកបាកាន ពួកខ្មែរក្រោម និងក្រោយមក ពួកអ្នកជម្លៀសភូមិភាគបូព៌ា ត្រូវបានគេប្រមូលផ្តុំជាដំណាក់កាល និងសម្លាប់ចោលយ៉ាងរង្គាល។ ខ្មែរក្រហម បានតម្លើងក្រោលបណ្តោះអាសន្ន ដើម្បីដាក់ជនរងគ្រោះមុននឹងសម្លាប់ចោល។ បន្ទាប់ពីការ

រលំដួលនៃរបបខ្មែរក្រហម រណ្ដៅនានាដែលពោរពេញទៅដោយសាកសព ត្រូវបានគេរកឃើញនៅទីកន្លែងចំនួនពីរកន្លែង ដែលមានមនុស្សរាប់ពាន់នាក់ត្រូវបានគេប៉ាន់ប្រមាណថាត្រូវបានសម្លាប់ចោល។

14. <u>នៅទីតាំងសម្លាប់មនុស្សវត្តច័ន្ទរង្សីក្នុងស្រុកបាកាន</u> កម្មាភិបាលខ្មែរក្រហមបានធ្វើប្រតិបត្តិការសម្លាប់រង្គាលនៃពួកអ្នកជម្លៀសភូមិភាគបូព៌ា នៅចុងឆ្នាំ១៩៧៨។ ពួកអ្នកមូលដ្ឋានត្រូវបានបង្ខំឲ្យកប់សាកសពដែលប៉ាន់ប្រមាណថាមានសរុប ២០០០នាក់ នៅក្នុងរណ្តៅសាកសពរួមនៅភូមិកូនត្នោត។

15. ពួកកម្មាភិបាលភូមិភាគនិរតី បានប្រព្រឹត្តជាច្រើន ដូចជា <u>អំពើហិង្សាខាងផ្លូវភេទនៅស្រុកបាកាន</u> ដោយពុំបានដាក់ទណ្ឌកម្មឡើយ។ អ្នកប្រព្រឹត្តបទល្មើសបាននិយាយអួតក្អេងក្អាងពីឧក្រិដ្ឋកម្មផ្លូវភេទរបស់ខ្លួនយ៉ាងចំហរ និងបង្កើនការកេងយកផលប្រយោជន៍ពីមុខតំណែងសិទ្ធិអំណាចរបស់ពួកគេ ដើម្បីរំលោភសេពសន្ថវៈលើស្ត្រី មុនពេលពួកគេបញ្ជាឲ្យសម្លាប់។ ការរំលោភសេពសន្ថវៈត្រូវបានកើតឡើងពាសពេញ ជាពិសេស ក្នុងកំឡុងពេលនៃការសម្លាប់រង្គាលរបស់ពួកខ្មែរក្រោម និងពួកអ្នកជម្លៀសភូមិភាគបូព៌ា នៅជិតចុងបញ្ចប់នៃរបបនោះ។

**តំបន់៣**

16. <u>មន្ទីរសន្តិសុខវត្តគិរីរម្យ</u> នៅក្នុងស្រុកភ្នំសំពៅ ត្រូវបានសាងសង់ឡើងនៅចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨ និងផ្ទុកអ្នកទោសច្រើនរហូតដល់ ២០០នាក់ រួមទាំងអតីតមន្ត្រីរដ្ឋការរបប លន់ នល់ និងកម្មាភិបាលភូមិភាគពាយ័ព្យ។ អ្នកទោសត្រូវបានធ្វើទារុណកម្ម និងបង្ខំឲ្យធ្វើការធ្ងន់ និងសម្លាប់ចោល។ សាកសពរាប់រយនាក់ត្រូវបានគេរកឃើញនៅវត្តនេះ និងនៅតាមជ្រលងក្បែរៗនោះ ក្រោយពេលរបបនោះបានដួលរលំ។ មិនមានអ្នកទោសណាម្នាក់ត្រូវបានគេដឹងថារួចជីវិតពីមន្ទីរសន្តិសុខនេះឡើយ។

**តំបន់ ៤**

17. នៅក្នុង<u>ឃុំវាំងកេសី និងឃុំកំពង់ព្រៀង</u> មានមនុស្សរាប់ពាន់នាក់មកពីតំបន់ ៤ ទាំងមូល ត្រូវបានសម្លាប់ ជាពិសេស ទាហាន លន់ នល់ កម្មាភិបាលពាយ័ព្យ និងខ្មែរក្រោម។ នៅកំពង់ព្រៀង កម្មាភិ បាលភូមិភាគពាយ័ព្យ ដែលត្រូវបានដកចេញពីដំណែង ត្រូវបានបង្ខំឲ្យធ្វើការក្នុងលក្ខខណ្ឌដូចជាទាសករ។ មនុស្សរាប់ពាន់នាក់ រួមទាំងកម្មាភិបាលភូមិភាគពាយ័ព្យ ជនជាតិវៀតណាម និងខ្មែរក្រោម ត្រូវបានឃុំខ្លួន ធ្វើទារុណកម្ម និងបង្អត់អាហារ នៅមន្ទីរសន្តិសុខកាច់រទេះ និងមន្ទីរសន្តិសុខសាលាត្រាវ។

18. នៅមន្ទីរសន្តិសុខវត្តសម្តេច ក្នុងស្រុកបាក់ព្រា អតីតសមាជិកនៃរបប លន់ នល់ រាប់ពាន់នាក់ និងក្រុមគ្រួសាររបស់ពួកគេ កម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ ជនជាតិវៀតណាម និងខ្មែរក្រោម និង "ប្រជាជន ១៧មេសា" ត្រូវបានសម្លាប់។ ការសម្លាប់រង្គាល បានកើតមានឡើងស្ទើរតែរាល់ថ្ងៃ។ រណ្តៅកប់សពចំនួន១១ ត្រូវបានរកឃើញនៅជុំវិញគុកនេះ ដោយរណ្តៅធំជាងគេបំផុតមានសាកសពពី ២០០០ ទៅ ៣០០០។

**តំបន់ ៧**

19. គុកលេខ ៨ ក្នុងស្រុកកណ្តៀងបានឃុំអតីតទាហាន លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ និងអ្នកជម្លៀសមកពីភូមិភាគបូព៌ា និងភ្នំពេញ។ អ្នកទោសជារឿយៗត្រូវទទួលរងទារុណកម្ម។ ការសម្លាប់កើតមានឡើងជារៀងរាល់យប់ ហើយស្ត្រីជាច្រើនត្រូវបានរំលោភសេពសន្ថវៈមុនពេលសម្លាប់។ រណ្តៅសាកសពរួមជាច្រើនដែលត្រូវបានរកឃើញនៅក្នុងតំបន់នេះបង្ហាញថា មានមនុស្សរាប់ពាន់នាក់ត្រូវបានសម្លាប់នៅទីតាំងនេះ។

20. ទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជើង ក្នុងស្រុកកណ្តៀង ត្រូវបានប្រើប្រាស់ចាប់ពីឆ្នាំ១៩៧៨ មក ដើម្បីសម្លាប់មនុស្សក្នុងចំនួនច្រើន ដែលត្រូវបានបញ្ជូនដោយបង្ខំពីភូមិភាគបូព៌ា មកកាន់ឃុំនានានៅជិតៗនោះក្នុងស្រុកកណ្តៀង។ អ្នកជម្លៀសមកពីភូមិភាគបូព៌ាមិនតិចជាងមួយពាន់នាក់ ត្រូវបានសម្លាប់នៅទីតាំងនេះ ហើយស្ត្រីជាច្រើនត្រូវគេរំលោភសេពសន្ថវៈមុនពេលសម្លាប់។

*ឧក្រិដ្ឋកម្មនៅភូមិភាគនិរតី និងពាយ័ព្យ ដែល យឹម ទិត្យ ត្រូវទទួលខុសត្រូវ*

1. អំពើប្រល័យពូជសាសន៍៖ យឹម ទិត្យ បានអនុវត្តផែនការរបស់ ប.ក.ក ដើម្បីកម្ទេចក្រុមជនជាតិវៀតណាមក្នុងប្រទេសកម្ពុជា តាមរយៈការសម្លាប់ជាតិពន្ធុវៀតណាម។ ជាផ្នែកនៃយុទ្ធនាការណ៍នេះ ខ្មែរក្រហមក៏បានកំណត់គោលដៅខ្មែរក្រោមផងដែរ ដោយលើកឡើងថា ពួកគេមាន "ក្បាលយួនខ្លួនខ្មែរ"។ ខ្មែរក្រោមត្រូវបាននាំមកកាត់តាមព្រំដែនចូលមកកាន់ស្រុកគិរីវង់ នៅពេលដែល យឹម ទិត្យ ទទួលបន្ទុកតំបន់នេះ បន្ទាប់មកពួកគេត្រូវបានសម្លាប់រង្គាល។ នៅភូមិភាគពាយ័ព្យ ក្រោយពេលដែល យឹម ទិត្យ មកដល់ និងកម្មាភិបាលភូមិភាគនិរតីបានគ្រប់គ្រងភូមិភាគនេះ ខ្មែរក្រោមត្រូវបានសម្លាប់ជាប្រព័ន្ធ ជាពិសេស នៅស្រុកបាកាន។

2. <u>ការបោសសម្អាតកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់៖</u> យឹម ទិត្យ បានធ្វើការជាមួយ តាម៉ុក និងកម្មាភិបាលភូមិភាគនិរតីផ្សេងៗទៀតដើម្បីធ្វើការ "បោសសម្អាត" ជាប្រព័ន្ធ ទាំងកម្មាភិបាលស៊ីវិល និងយោធានៃភូមិភាគពាយ័ព្យ ចេញពីមុខតំណែងដឹកនាំរបស់ពួកគេ។ ពួកគេបានចាត់ទុកកម្មាភិបាលពាយ័ព្យថាជា "ខ្មាំង" ឬជាជនក្បត់ និងបានចាប់ខ្លួន បានឃុំឃាំងពួកអ្នកទាំងនោះ និងចុងបញ្ចប់បានសម្លាប់ពួកគេចោល។ អ្នកទាំងឡាយណាដែលជាប់ទាក់ទងជាមួយនឹងកម្មាភិបាលដែលត្រូវបានដកចេញពីតំណែងទាំងនោះ ក៏ត្រូវបានគេចាត់ទុកថាជា "ជនក្បត់" ផងដែរ ដូច្នេះ អ្នកក្រោមបង្គាប់ និងក្រុមគ្រួសាររបស់ពួកគេជាច្រើនក៏ទទួលរងនូវជោគវាសនាដូចគ្នានេះដែរ។ ខណៈដែលមនុស្សជាច្រើនត្រូវបានសម្លាប់នៅក្នុងភូមិភាគពាយ័ព្យ ឯកសារគុក ស-២១ ដែលនៅសេសសល់បង្ហាញថា ចាប់ពីថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៧ រហូតដល់ចុងបញ្ចប់នៃរបបនោះ យ៉ាងហោចណាស់មានមនុស្ស ១០១០ នាក់ មកពីភូមិភាគពាយ័ព្យ ត្រូវបានបញ្ជូនទៅកាន់គុកនៅភ្នំពេញ។

3. <u>អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ៖</u> យឹម ទិត្យ បានរួមចំណែកក្នុងគោលនយោបាយបង្ខំឲ្យប្រជាជនកម្ពុជារៀបការ និងរួមសង្វាសដើម្បីបង្កើនចំនួនប្រជាជនឲ្យបានឆាប់រហ័ស។ នៅតំបន់ ១ (ស្រុកសំឡូត និងរោងចក្រស្ករសកំពង់គល់) និង តំបន់៤ (ឃុំវាំងកេសី និងឃុំកំពង់ព្រៀង) អ្នកក្រោមបង្គាប់របស់ យឹម ទិត្យ បានរៀបចំពិធីរៀបអាពាហ៍ពិពាហ៍ជាក្រុមឲ្យមនុស្សរាប់រយនាក់ ដែលត្រូវបានផ្គូផ្គងដោយរបបនោះ ដោយមិនមានការព្រងព្រៀងដោយសេរីឡើយ។ បន្ទាប់មក គូស្រករទាំងនោះត្រូវបានគេរំពឹងថានឹងរួមសង្វាស់ជាមួយគ្នា។ យឹម ទិត្យ បានថ្លែងសន្ទរកថាដោយផ្ទាល់នៅក្នុងពិធីអាពាហ៍ពិពាហ៍ដោយបង្ខំមួយ ដែលមានគូស្រករចំនួន ៣៨គូ នៅក្នុងស្រុកសំឡូត ដែលនៅក្នុងនោះគាត់បានប្រាប់គូស្រករទាំងនោះថាពួកគេ "ត្រូវចេះស្រឡាញ់គ្នា" បន្ទាប់មកបានផ្តល់សម្ភារៈដេកឲ្យពួកគេ។ អ្នកដែលរៀបការថ្មីៗត្រូវបានតាមដានដោយពួកឈ្លប ដើម្បីធានាថាពួកគេបានរួមសង្វាស់ ហើយ យឹម ទិត្យ បានណែនាំឲ្យថ្នាក់ក្រោមរបស់គាត់តាមដានអត្រាកំណើតប្រចាំខែ។ ជាលទ្ធផលនៃវិធានការទាំងនេះ គូស្រករជាច្រើនបានរួមភេទដើម្បីចៀសវាងទណ្ឌកម្មធ្ងន់ធ្ងរ។ ស.ព.អ អះអាងថា បុរស និងស្ត្រីដែលត្រូវបានបង្ខំឲ្យរួមភេទដោយមិនមានការព្រមព្រៀងពិតប្រាកដបែបនេះបង្កើតបានជាការរំលោភសេពសន្ថវៈ។

## <u>ដំណាក់កាលបន្ទាប់ក្នុងរឿងក្តី យឹម ទិត្យ</u>

បច្ចុប្បន្ននេះ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាបានដាក់រួចហើយ ដូច្នេះក្រុមមេធាវីការពារក្តីមានឱកាសឆ្លើយតបជាមួយនឹងទស្សនៈរបស់ខ្លួនលើអង្គច្បាប់ និងភ័ស្តុតាង។ បន្ទាប់មកសហចៅក្រមស៊ើប

អង្កេតត្រូវសម្រេចថាតើ យឹម ទិត្យ ស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬយ៉ាងណា និងថាតើ ការស៊ើបអង្កេតនេះបានបង្ហាញអំពីការទទួលខុសត្រូវរបស់ យឹម ទិត្យ ចំពោះឧក្រិដ្ឋកម្មទាំងឡាយនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដល់បទដ្ឋានដែលត្រូវការដើម្បីចោទប្រកាន់ និងបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ ឬយ៉ាងណា។ ដូចគ្នាទៅនឹងជនត្រូវចោទ និងជនជាប់ចោទនៅ អ.វ.ត.ក ដែរ យឹម ទិត្យ ទទួលបានការសន្មតថាគ្មានទោស លើកលែងតែ និងរហូតទាល់តែពិរុទ្ធភាពត្រូវបានបង្ហាញនៅពេលជំនុំជម្រះ និងត្រូវបានតម្កល់ដោយបណ្តឹងសាទុក្ខណាមួយប៉ុណ្ណោះ។

ដូចបានគូសបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ស.ព.អ ជឿជាក់ថា ការបញ្ជូនខ្លួន យឹម ទិត្យ ទៅជំនុំជម្រះ នឹងមិនប៉ះពាល់ដល់ការផ្សះផ្សាជាតិ ស្ថេរភាព សន្តិភាព ឬសន្តិសុខក្នុងប្រទេសកម្ពុជានោះទេ។ គាត់បានកត់សម្គាល់ថា ការកាត់ឲ្យជាប់ទោស និងការដាក់ទោសជាប់ពន្ធនាគារមួយជីវិត ដែលធ្វើឡើងនៅក្នុងសំណុំរឿង០០១ (ប្រឆាំងនឹង កាំង ហ្គេកអ៊ាវ *ហៅ* ឌុច) និងសំណុំរឿង០០២/០១ (ប្រឆាំងនឹង នួន ជា និងខៀវ សំផន) មិនមានផលប៉ះពាល់អវិជ្ជមានលើការផ្សះផ្សាជាតិ ស្ថេរភាព សន្តិភាព សន្តិសុខក្នុងប្រទេសកម្ពុជាឡើយ ប៉ុន្តែផ្ទុយទៅវិញ ជារឿយៗទទួលបានការកោតសសើរចំពោះផលវិជ្ជមានជាច្រើនរបស់ខ្លួន រួមមានការផ្តល់វិធានការយុត្តិធម៌មួយចំនួនដល់ជនរងគ្រោះខ្មែរក្រហម។ ជាងនេះទៀត មិនមានប្រតិកម្មអវិជ្ជមានពីសាធារណជនចំពោះការបង្ហាញថា យឹម ទិត្យ និងជនសង្ស័យផ្សេងទៀតត្រូវបានស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង០០៤ ឡើយ។ តាមទស្សនៈរបស់ ស.ព.អ ការខិតខំប្រឹងប្រែងដាក់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យថ្នាក់ខ្ពស់ឲ្យទទួលខុសត្រូវចំពោះអំពើរបស់ពួកគេទាំងនោះ នឹងបង្កើនទំនុកចិត្តសាធារណជនថា ជនមានឥទ្ធិពលមិនអាចចៀសផុតពីការទទួលខុសត្រូវជារៀងរហូតចំពោះឧក្រិដ្ឋកម្មរបស់ខ្លួនបានឡើយ និងថាយុត្តិធម៌អាចសម្រេចបាន។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក **នេត្រ ភក្ត្រា**

ប្រធានផ្នែកកិច្ចការសាធារណៈនិង ជាមន្ត្រីនាំពាក្យនៃសាលាក្តីខ្មែរក្រហម

ទូរស័ព្ទ៖ +៨៥៥ (0) ១២ ៤៨៨ ១៥៦

អ៊ីមែល៖ NETH.Pheaktra@eccc.gov.kh